# សេចក្តីសង្ខេប
# អំពីបញ្ហាសុខភាពខាងផ្លូវចិត្តនៃជនជាតិអាស៊ីនៅនូវស៊ីឡែន
# រៀបរៀងឡើងសំរាប់
## គណៈកម្មការសុខភាពខាងផ្លូវចិត្ត (Mental Health Commission)

Elsie Ho, Sybil Au, Charlotte Bedford and Jenine Cooper
Migration Research Group, Department of Geography
University of Waikato

## ពាក្យផ្តើម

អត្ថបទនេះជាសេចក្តីសង្ខេបចេញពីសៀវភៅពិស្តារមួយដែលរៀបរៀងឡើងសំរាប់គណៈកម្មការសុខភាពខាងផ្លូវចិត្ត ក្រោមចំណងជើងថា "បញ្ហាសុខភាពខាងផ្លូវចិត្តនៃជនជាតិអាស៊ីនៅនូវស៊ីឡែន (Mental Health Issues for Asians in New Zealand)។ សៀវភៅនេះជាឯកសាររបស់គណៈកម្មការសុខភាពខាងផ្លូវចិត្តដែលផ្តោតអារម្មណ៏គិតគូរចំពោះជនជាតិអាស៊ីមុនដំបូងបង្អស់ ។ រហូតមកទល់ពេលនេះ ប្រជាជនអាស៊ី ព្រមជាមួយការគិតគូរអំពីបញ្ហាសុខភាពខាងផ្លូវចិត្តផ្ទាល់ គឺឥតមានអ្នកណាចាប់អារម្មណ៏ទៅលើប៉ុន្មានទេ ទោះបីជាពួកគេមានគ្នាច្រើន ហើយកំពុងតែរីកដុះដាលកាន់តែច្រើនឡើងទៀត នៅក្នុងសង្គមនូវស៊ីឡែនក្តី ។

គេរមែងមានជំនឿមួយថា ជនជាតិអាស៊ីប៉ុនប្រសព្វសំរបសំរួលខ្លួនតាមគេបានល្អប្រសើរណាស់ ដូចមានភ័ស្តុតាងបញ្ជាក់តាមអត្រាក៏រិតយ៉ាងទាបក្នុងរឿងឧក្រិដ្ឋកម្ម និងរៀងលែងលះគ្នា ក៏ដូចជាការសំរេចក្នុងគោលដៅនៃការសិក្សាជាន់ខ្ពស់ និងការងាររបស់គេដែរ ។ ខ្លឹមសារនៃអត្ថបទនេះ និងប្រឈមមុខដោះស្រាយបញ្ហាសុខមាលភាពជាប្រពៃណីឥតប្រែប្រួលមួយ ព្រមទាំងសុខភាពខាងផ្លូវចិត្តនៃបណ្តារជនជាតិអាស៊ី ។ ខ្លឹមសារនៃអត្ថបទនេះក៏និងជួយទាក់ទាញអារម្មណ៏គេឱ្យជួយផ្តល់ចម្លើយច្រើនទៀតក្នុងបំណងបំពេញសេចក្តីត្រូវការនៃអ្នកដែលប្រើប្រាស់ក្រុមបំរើការសំរាប់ជាតិអាស៊ី និងក្រុមគ្រួសាររបស់គេក្នុងបែបបទសុខភាពខាងផ្លូវចិត្ត ។

ប្រជានជនអាស៊ីនៅនូវស៊ីឡែនមានចែកជាក្រុមអណិកជនជាតិផ្សេងៗច្រើនក្រុម ។ ដោយហេតុថាមានកំណត់លើពេលវេលា និងធនធាននោះ ការធ្វើវិភាគស្ថិតិក្នុងរបាយការណ៏នេះត្រូវផ្តោតឆ្ពោះទៅលើអណិកជន៥ក្រុមគឺ : អណិកជនចិន, ឥណ្ឌា, កូរ៉េ, ខ្មែរ និងវៀតណាម ។

របាយការណ៏និងពិនិត្យជាបឋមអំពីបញ្ហាសុខភាពខាងផ្លូវចិត្តនៃក្រុមអ្នកចូលមកតាំងលំនៅថ្មី និងក្រុមសិស្សានុ-សិស្សជាតិអាស៊ីដែលចូលមករៀនសូត្រដោយបង់តម្លៃសិក្សា ។

## អំពីទម្រង់នៃសង្គម_សេដ្ឋកិច្ច (Socioeconomic profile)[1]

ជនជាតិអាស៊ីនៅនូវស៊ីឡែនសុទ្ធសិងតែកាន់សាសនា មានទំនៀមទម្លាប់ និយាយភាសារ ទទួលការសិក្សា ហើយនិងមានបទពិសោធន៏ផ្នែកសង្គម-សេដ្ឋកិច្ចប្លែកៗពីគ្នាទាំងអស់ ។ ទោះបីយ៉ាងនេះក្តី ក្នុងករណីទូទៅ ក្រុមអ្នកចូលមកតាំងលំនៅថ្មីដែលមានសិទ្ធិជ្រកកោនជាអចិន្ត្រៃយ៏នៅនូវស៊ីឡែនក្រោមរយៈពេល១០ឆ្នាំ សុទ្ធសិងតែចេះភាសារអង់គ្លេសតិចតួចណាស់ ឯការសិក្សាក៏ខុសៗគ្នាដែរ ចំនួនអត្រាអ្នកគ្មានការងារធ្វើមានកំរិតលើសពីរដងនៃចំនួនប្រជាជនទាំងមូល ពោលគឺស្ថិតនៅក្រោមកំរិតប្រាក់ចំណូលមធ្យមប្រចាំឆ្នាំ និងប្រព័ន្ធនៃអាយុក្រុមយុវវ័យ ។

## អំពីបញ្ហាសំរបសំរួលខ្លួន និងឧបស័គ្គផ្សេងៗ

តាមរបាយការណ៏នៃគណៈកម្មការសុខភាពខាងផ្លូវចិត្តបានបង្ហាញអោយដឹងថា
ជនជាតិអាស៊ីនៅនូវស៊ីឡែនខ្លះបានប្រឈមមុខចំពោះបញ្ហាសំរបសំរួលខ្លួនយ៉ាងខ្លាំងដូចជា :

- បញ្ហាភាសារ
- បញ្ហាការងារ

---

[1] ពត៌មានក្នុងភាគនេះបានដកស្រង់ចេញពីឯកសារមិនទាន់បោះពុម្ពផ្សាយមួយ-រៀបរៀងឡើងដោយក្រុមជំនួយភ្ញៀវអ្នកទិញឥវ៉ាន់ផ្នែកស្ថិតិប្រជាជននូវស៊ីឡែននៃបញ្ជីរជំរឿនប្រជាជន និងលំនៅដ្ឋានឆ្នាំ២០០១ ។

- បញ្ហាបែកបាក់គ្រួសារ និងប្រព័ន្ធទ្រទ្រង់ផ្នែកសង្គមនានា រួមទាំងការរស់នៅឃ្លាតឆ្ងាយពីគ្រួសារផង
- ភាពតានតឹងនិងការសំរបសំរួលខ្លួនទៅតាមទំនៀមទម្លាប់របស់គេ (នេះគឺសំដៅលើភាពតានតឹងកើតឡើងនៅពេលដែលមនុស្សនៃក្រុមវប្បធម៌ណាមួយស្ថិតនៅលាយឡំជាមួយក្រុមវប្បធម៌មួយទៀត)
- ភាពខ្វះខាតក្នុងការទទួលរាក់ទាក់ជាមិត្តភាពពីសំណាក់ម្ចាស់ស្រុក
- ភាពភ័យតក់ស្លុតដោយខ្វះបទពិសោធន៏ផ្សេងៗនៅពេលមុន និងនៅពេលចូលមកតាំងលំនៅថ្មី - ទាំងអស់នេះអាចរួមបញ្ចូលនូវភាពភ័យតក់ស្លុត ហើយនិងទារុណកម្មដ៏សាហាវផ្សេងៗផងដែរ
- ភាពលះបង់នូវឋានៈ សង្គម - សេដ្ឋកិច្ចផ្ទាល់ខ្លួនបន្ទាប់ពីពេលចូលមកតាំងលំនៅថ្មី ។

## តើគេប្រៀបធៀបអត្រានៃជម្ងឺខាងផ្លូវចិត្តយ៉ាងដូចម្តេច ?

តាមការកំណត់ស្រាវជ្រាវរកឃើញផ្សេងៗ បានបញ្ជាក់ឱ្យដឹងថា កំរិតនៃសុខភាពខាងផ្លូវចិត្តក្នុងបណ្តាជនជាតិអាស៊ីមិនសូវខុសប្លែកខ្លាំងពីប្រជាជនទូទៅឯទៀតប៉ុន្មានទេ ។ ក្នុងការសិក្សាដ៏ទៃទៀតក៏បានចង្អុលបញ្ជាក់ផងដែរថា ការក្រៀមក្រំខាងផ្លូវចិត្តមានអត្រាខ្ពស់ណាស់ក្នុងបណ្តាជនជាតិចិនចាស់ៗដែលជាអ្នកចូលមកតាំងលំនៅថ្មី ។ ក្នុងចំណោមជនភៀសខ្លួនខ្មែរ មានភាគច្រើនត្រូវរងគ្រោះដោយភាពរើរវាយ តានតឹងក្នុងចិត្តបណ្តាលមកពីភាពតក់ស្លុតពីមុនមក (post-traumatic stress disorder / PTSD) ។

## អំពីឧបស័គ្គដែលរារាំងមិនអោយគេបានចូលទៅរកជំនួយខាងផ្លូវចិត្ត

ជម្ងឺខាងផ្លូវចិត្តជាជម្ងឺដែលយាយីទំនៀមទម្លាប់ជនជាតិអាស៊ីយ៉ាងខ្លាំង ។ ព្រោះហេតុដូច្នេះហើយបានជាបណ្តាជនជាតិអាស៊ីស្ទាក់ស្ទើរក្នុងចិត្តណាស់ក្នុងការរកជំនួយដើម្បីថែរក្សាព្យាបាលសុខភាពខាងផ្លូវចិត្តរបស់ខ្លួន ឬបើពុំដូច្នោះទេក៏គេរកលេសពន្យាពេលរកជំនួយថែរក្សាព្យាបាលនោះរហូតទាល់តែសមាជិកនៃគ្រួសារដែលកើតបញ្ហាមិនអាចទ្រាំទ្របាន ។ ក្នុងបណ្តាជនជាតិអាស៊ីដែលទើបបានចូលមកតាំងលំនៅថ្មី នៅមានបញ្ហាខ្វះជំនាញខាងភាសាអង់គ្លេស ចំណេះវិជ្ជាមិនគ្រប់គ្រាន់ ហើយនិងភាពមិនបានដឹងឮអំពីវត្តមាននៃក្រុមជំនួយផ្សេងៗ ព្រមជាមួយនិងភាពផ្ទុយគ្នានៃទំនៀមទំលាប់ក្នុងការប៉ាន់ស្មានវាយតម្លៃនិងការព្យាបាលជម្ងឺខាងផ្លូវចិត្ត - បញ្ហាទាំងអស់នេះជាឧបស័គ្គដែលរារាំងបន្ថែមទៅលើការប្រើប្រាស់បែបបទរក្សាព្យាបាលសុខភាពខាងផ្លូវចិត្តរបស់គេ ។

## ការផ្តល់ឱវាទ ដើម្បីផ្សព្វផ្សាយរឿងសុខភាពខាងផ្លូវចិត្តនៅក្នុងសហគមអាស៊ី

- បង្កើនការជួយគាំទ្រនៃសាធារណៈជនចំពោះទំនៀមទំលាប់ជាតិផ្សេងៗ ។ ក្នុងចំណោមកត្តាជាច្រើនទៀតដែលបញ្ជាក់ថា តើការចូលមកតាំងលំនៅថ្មីជាបទពិសោធន៏ល្អឬមិនល្អ - ការចាប់អារម្មណ៏នៃអ្នកម្ចាស់ស្រុកចំពោះអ្នកចំណូលថ្មី ហើយនឹងចិត្តសន្តោសរបស់គេចំពោះទំនៀមទម្លាប់ជាតិផ្សេងៗ ទាំងអស់នេះគឺជាបញ្ហាសំខាន់ណាស់
- ជួយផ្តល់ពត៌មានឱ្យបានទូលំទូលាយ នៅមុននិងក្រោយពេលចូលមកតាំងលំនៅថ្មី គោលសេចក្តីសំខាន់គួររួមបញ្ចូលនូវបញ្ហាការងារ លំនៅដ្ឋាន សាលារៀន ការហ្វឹកហ្វឺនភាសារ និងទំនាក់ទំនងផ្នែកសង្គមនិងវប្បធម៌
- កែច្នៃឱ្យមានលទ្ធភាពអាចចូលសិក្សាភាសារអង់គ្លេសបានស្រួល
- ជួយលើកទឹកចិត្ត និងគាំទ្រការអភិវឌ្ឍន៏នៃកម្មវិធីទ្រទ្រង់សហគម

## ការផ្តល់ឱវាទដើម្បីកែច្នៃឱ្យមានចម្លើយតបពីរឿងទំនៀមទំលាប់ចំពោះក្រុមជំនួយសុខភាពខាងផ្លូវចិត្ត

- ជួយផ្សព្វផ្សាយអំពីការអភិវឌ្ឍន៏ផ្នែកសម្ភារៈសិក្សា និងអ្នកមានវិជ្ជាជីវៈខាងបកប្រែភាសារ ។
- បង្កើនការរំឭកដាស់តឿនចំពោះក្រុមផ្តល់ជំនួយនានាឱ្យបានជ្រាបពីបញ្ហាទំនៀមទម្លាប់ជាតិអាស៊ី ។

## ក្រុមមនុស្សដែលជាឧបស័គ្គខ្លាំងសំរាប់ការស្រាវជ្រាវក្នុងអនាគត

- ក្រុមស្ត្រីភេទ
- ក្រុមសិស្សានុសិស្ស
- ក្រុមមនុស្សចាស់ៗ
- ក្រុមជនភៀសខ្លួន

[Khmer]